# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៥. សសរ

## សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការជាតិ ដើម្បីអនុវត្តផែនការសកម្មភាពស្តីពីយុទ្ធសាស្ត្រ នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច បួនប្រទេស កម្ពុជា ឡាវ មីយ៉ាន់ម៉ា និង ថៃ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**ប្រការ ១:** បង្កើតគណៈកម្មការជាតិមួយមានឈ្មោះថា" គណៈកម្មការជាតិដើម្បីអនុវត្តផែនការសកម្មភាព ស្តីពីយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច បួនប្រទេស កម្ពុជា ឡាវ មីយ៉ាន់ម៉ា និង ថៃ" ដែលមានសមាសភាព ដូចតទៅ :

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម ហោ ណាំហុង | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| ២- | ឯកឧត្តម ចម ប្រសិទ្ធ | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣- | ឯកឧត្តម ចាន់ សារុន | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ | សមាជិក |
| ៤- | ឯកឧត្តម ស៊ុយ សែម | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៥- | ឯកឧត្តម ត្រាំ អ៊ីវតឹក | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៦- | ឯកឧត្តម ថោង ខុន | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៧- | ឯកឧត្តម ត្រាំ សុខា | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |

| | | |
|---|---|---|
| ៨- ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** | ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | សមាជិក |
| ៩- ឯកឧត្តម **សុខ ចិន្តា** | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១០-ឯកឧត្តម **ហង់ ជួនណារ៉ុន** | អគ្គលេខាធិការឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | អគ្គលេខាធិការ |

**ប្រការ ២:** គណៈកម្មការជាតិនេះ មានភារកិច្ចដូចតទៅ :

- ពិភាក្សាជាមួយប្រទេសជាដៃគូ ក្នុងយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ជាពិសេសជាមួយប្រទេសថៃ ដើម្បីជំរុញការអនុវត្តផែនការសកម្មភាព អោយស្របតាមពេលវេលាកំណត់ ។
- អាចលើកគំរោងចរចាដោយផ្ទាល់ រវាងស្ថាប័នពាក់ព័ន្ធក្នុងយុទ្ធសាស្ត្រ នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ដើម្បីជំរុញការអនុវត្តផែនការសកម្មភាព ។
- អាចពិភាក្សាលើកគំរោងផ្សេងទៀត ក្រៅពីផែនការសកម្មភាពស្តីពីយុទ្ធសាស្ត្រ នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ស្នើជូនរាជរដ្ឋាភិបាល ដើម្បីបញ្ចូលក្នុងផែនការសកម្មភាពទៅអនាគត ។
- ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល អំពីលទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រ នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ។

**ប្រការ ៣:** គណៈកម្មការជាតិនេះ មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំ ឬតំណាងក្រសួង-ស្ថាប័ន ដែលមានការពាក់ព័ន្ធនឹងការងារ ក្នុងក្របខណ្ឌយុទ្ធសាស្ត្រ នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច បួនប្រទេស កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងថៃ ឬការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមជាតិ ដើម្បីចូលរួមបំពេញការងារ តាមការជាក់ស្តែង ។

**ប្រការ ៤:** សមាជិកទាំងអស់នៃគណៈកម្មការជាតិនេះ ត្រូវចូលរួមប្រជុំ និង ធ្វើការងារតាមសេចក្តីអញ្ជើញ និងការណែនាំរបស់ប្រធាន ។

**ប្រការ ៥:** គណៈកម្មការជាតិនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាផ្លូវការ ។

**ប្រការ ៦:** គណៈកម្មការជាតិនេះ មានលេខាធិការដ្ឋានមួយ ដែលស្ថិតនៅក្នុងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**ប្រការ ៧:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និង សាមីខ្លួន ដែលមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៣*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**ចំលងជូន:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៧
- ឯកសារ-កាលប្បវត្តិ